**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលព្រៃឈើ**
**នាយកដ្ឋានព្រៃឈើនិងសហគមន៍ព្រៃឈើ**

ភ្នំពេញ ថ្ងៃទី ខែមេសា ឆ្នាំ២០១៤

**ក្រុមការងារ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV/REL)**
**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

**កម្មវត្ថុៈ** របាយការណ៍ស្តីពីលទ្ធផលអង្គប្រជុំបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់(MRV/REL) លើកទី៧។

**ជូនភ្ជាប់:** - បញ្ជីវត្តមាន..........................................................................................ចំនួន១ច្បាប់
- ពង្រាងផែនការសកម្មភាព....................................................................ចំនួន១ច្បាប់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើយើងខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមប្រតិភូមេត្តាជ្រាបថាកាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៤ ក្រុមការងារបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV/REL) បានរៀបចំកិច្ចប្រជុំលើកទី៧ នៅសណ្ឋាគារ អ៊ីមភីរៀលហ្គាឌិនវីឡា ដែលទទួលបានលទ្ធផលដូចខាងក្រោមៈ

## ១. សមាសភាពចូលរួម

កិច្ចប្រជុំនេះមានសមាជិកចូលរួមចំនួន ០៩នាក់ (ដូចបញ្ជីវត្តមាននៃឯកសារជូនភ្ជាប់) មកពីៈ
- ស្ថាប័នរាជរដ្ឋាភិបាលៈ រដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន
- ជំនាញការអន្តរជាតិៈ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) ។

## ២. គោលបំណងនៃអង្គប្រជុំ

-អង្គប្រជុំមានគោលបំណងធ្វើការពិនិត្យឡើងវិញ និងកែសម្រួល លើសេចក្តីព្រាងផែនការសកម្មភាព របស់ MRV/REL។

-បន្តពិភាក្សាលើការរៀបចំផែនការបច្ចេកទេសបង្កើត REL (Base Map) ។

-បញ្ហាផ្សេងៗ។

## ៣. ដំណើរការកិច្ចប្រជុំ

-អង្គប្រជុំបានបន្តធ្វើការពិនិត្យ និងកែសម្រួលឡើងវិញ លើខ្លឹមសារក្នុងសេចក្តីព្រាងផែនការសកម្មភាព REL/MRV ចាប់ពី Output ៤.១ និងធ្វើការកំណត់លើតារាងពេលវេលាសម្រាប់អនុវត្តសកម្មភាពនីមួយៗ។

- លោក Mathieu van Rijn បានធ្វើបង្ហាញសង្ខេបចែករំលែកអំពីជម្រើសនិយមន័យព្រៃឈើ និងនិយមន័យការប្រើប្រាស់ដីព្រៃឈើ ដើម្បីជាចំណេះដឹង ព័ត៌មានដល់សមាជិកក្រុមការងារ MRV/REL សម្រាប់មាន

មូលដ្ឋានគ្រប់គ្រាន់ក្នុងការជ្រើសរើសយកនិយមន័យណាមួយដែលសមស្រប និងត្រឹមត្រូវសម្រាប់អនុវត្តក្នុងកម្មវិធីរេដ។ បន្ទាប់មក អ្នកជំនាញការមកពីប្រទេសអ៊ីតាលី បានធ្វើបទបង្ហាញស្ដីពីសំណាកព័រថល (Web platform) របស់ប្រព័ន្ធតាមដានព្រៃឈើថ្នាក់ជាតិ។

-អ្នកជំនាញការមកពីប្រទេសជប៉ុន លោក Shigeru Ono បានភ្ជាប់ទំនាក់ទំនងតាមរយៈ Skype បង្ហាញនូវវិធីរៀបចំ Base Map សម្រាប់ជារបាយការណ៍ដល់កម្មវិធីរេដកម្ពុជា ផ្ញើរទៅ UNFCC នាបំណាច់ឆ្នាំ ២០១៦ខាងមុខ។ ក្នុងនោះផងដែរ ក៏មានការបង្ហាញជាផែនការយុទ្ធសាស្រ្តក្នុងការរៀបចំសកម្មភាព ក៏ដូចជាបច្ចេកទេសលម្អិតដល់អង្គប្រជុំ។

## ៤. លទ្ធផលនៃអង្គប្រជុំ

-អង្គប្រជុំបានសម្រេចនូវសេចក្ដីព្រាងផែនការសកម្មភាព MRV/RELនិងបានកំណត់តារាងពេលវេលាសម្រាប់អនុវត្តសកម្មភាពនីមួយៗ លើចំណុចទី Output ៤.១ និង Output ៤.២(សកម្មភាព ៤.២.១ ដល់៤.២.៤) ព្រមទាំងកំណត់អ្នកទទួលខុសត្រូវអនុវត្តសកម្មភាពនិមួយៗ

-អង្គប្រជុំបានឯកភាពនឹងសិក្សាលើឯកសារយោងបន្ថែមទៀត លើកំណត់និយមន័យគម្របព្រៃឈើសម្រាប់អនុវត្តក្នុងកម្មវិធីរេដកម្ពុជា

- អង្គប្រជុំឯកភាពឲ្យអ្នកជំនាញការ ធ្វើការបន្តរៀបចំ Web platform ឲ្យបានចប់សព្វគ្រប់ ហើយដាក់ជូនថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើពិនិត្យ និងសម្រេច។

- ចំពោះការបង្កើត Base Map គាំទ្រដល់ការរៀបចំសកម្មភាព REL អ្នកជំនាញការ CAM-REDD ប្រទេសជប៉ុន បានឯកភាពជាមួយក្រុមការងារ សិក្សាលើចំណុចជាយុទ្ធសាស្រ្តសំខាន់ៗមួយចំនួន បូកនឹង Concept Note ដែលជាមូលដ្ឋានគ្រឹះក្នុងការបង្កើត Base Map រួចនឹងដាក់ជូនថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើដើម្បីសម្រេចនាពេលខាងមុខ។

## ៥. ទិសដៅអនុវត្តបន្ត

-ក្រុមការងារនឹងរៀបចំកិច្ចប្រជុំលើក៨ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ដើម្បីធ្វើការពិភាក្សាបន្តដើម្បីបញ្ចប់សេចក្ដីព្រាងផែនការសកម្មភាពREL/MRV មុននឹងដាក់ជូនថ្នាក់ដឹកនាំធ្វើការពិនិត្យសម្រេចជាផ្លូវការ

-ក្រុមការងារ REL/MRV បន្តជួបពិភាក្សា និងសហការជាមួយអ្នកជំនាញការអន្តរជាតិ ដើម្បីជំរុញការអនុវត្តការងារ REL/MRV អោយដំណើរការមុខដោយរលូន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាជ្រាបជាសេចក្ដីរាយការណ៍ ដោយអនុគ្រោះតាមការគួរ ។